**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 28-Jan-2015, 15:11
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ

ហត្ថលេខា:

---

**សំណើតាមវិធាន ៨៧(៤) របស់ នួន ជា ស្នើសុំឲ្យទទួលយកឯកសារ ទាក់ទងនឹង ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី**

---

| <u>ដាក់ដោយ៖</u> | **<u>ផ្ញើជូន៖</u>** |
|---|---|
| **ក្រុមមេធាវីការពារក្តី នួន ជា** | **សហាជនជាប់ចោទ** |
| សុន អរុណ | |
| Victor KOPPE | **សហព្រះរាជអាជ្ញា** |
| ព្រុំ ផល្លា | **លោកស្រី ជា លាង** |
| សួន វិសាល | **លោក Nicholas KOUMJIAN** |
| លីវ សុវណ្ណា | **សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី** |
| Doreen CHEN | **PICH Ang** |
| Xiaoyang NIE | **Marie GUIRAUD** |

អនុលោមតាមវិធាន ៨៧(៤) និងសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលសវនាការនៅថ្ងៃ ច័ន្ទ ទី ២៦ ខែ មករា ឆ្នាំ ២០១៥ មេធាវីការពារក្ដីលោក នួន ជា ("ក្រុមមេធាវីការពារក្ដី") តទៅនេះសូមដាក់សំណើសុំឲ្យទទួលយកឯកសារទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី (សំណើ)៖

## I. សង្ខេប

១. នៅថ្ងៃទី ២២, ២៣ និង ២៦ ខែ មករា ឆ្នាំ ២០១៥ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានផ្ដល់សក្ខីកម្មនៅចំពោះមុខនីតិវិធីក្នុងសំណុំរឿង ០០២/០២។ នៅក្នុងអំឡុងពេលការសួរដេញដោយលោកស្រី អ៊ុំ សុផានី មេធាវីការពារក្ដីបានយោងទៅដល់កិច្ចសម្ភាសន៍ដែលគាត់បានផ្ដល់ជូនការសែតភ្នំពេញបុស្តិ៍នៅឆ្នាំ ២០១៣ ដែលជាព័ត៌មានអាចរកបាននៅមជ្ឈដ្ឋានសាធារណៈ និង ដែលមេធាវីការពារក្ដីមិនបានដាក់ចូលក្នុងឃ្លាំងសម្រាប់ឯកសារសវនាការ។ បន្ទាប់ពីមានការជំទាស់គ្នា និងការពិភាក្សាគ្នាយ៉ាងច្រើនមក អង្គជំនុំជម្រះបានសម្រេចនៅព្រឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ថា សំណួរពាក់ព័ន្ធនឹងឯកសារដែលមិនទាន់ដាក់ចូលក្នុងសំណុំរឿងនឹងមិនត្រូវបានអនុញ្ញាតិនោះទេ "សម្រាប់ពេលនេះ"។ ក៏ប៉ុន្តែ ប្រសិនបើមេធាវីការពារក្ដី គិតថា ខ្លួនមានឯកសារទាក់ទងនឹងសក្ខីកម្មរបស់អ្នកស្រី អ៊ុំ សុផានី ដែលឯកសារនោះបំពេញបានតាមលក្ខខណ្ឌវិធាន ៨៧ (៤) នោះមេធាវីមានរយៈពេល ៤៨ ម៉ោង ដើម្បីដាក់ឯកសារទាំងនេះចូលក្នុង "ឃ្លាំងផ្ទុកឯកសាររួម" ដើម្បីឲ្យភាគីដ៏ទៃទៀតពិនិត្យ។ បន្ទាប់ពីពិនិត្យរួចហើយលោកស្រី អ៊ុំ សុផានី អាចត្រូវបានកោះអញ្ជើញឲ្យមកផ្ដល់សក្ខីកម្មបន្ថែមទៀត ប្រសិនបើចាំបាច់[1]។

## II. អំណះអំណាង

### ក. បញ្ហាបឋម

[1] "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" (មានតែពង្រាងដោយមិនទាន់មានលេខ E1នៅឡើយទេ), ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ("សេចក្ដីព្រាងប្រតិចារិត ២៦ ខែ មករា ឆ្នាំ ២០១៥") ទំព័រ ១៣ បន្ទាត់ ១០ ទំព័រ ១៤ បន្ទាត់៣។

២. ដោយសារតែនេះជាបញ្ហាចំពោះមុខ មេធាវីការពារក្តីកត់សម្គាល់ថា ខ្លួនបានដាក់ឯកសារទាំងនេះចូលក្នុងឃ្លាំងផ្ទុកឯកសាររួមរួចហើយនៅព្រឹកនេះ ហើយដែលលេខ ERN ត្រូវបានបង្ហាញខាងនៅខាងក្រោមនេះ។ មេធាវីការពារក្តីចាត់ទុកថា នេះបានបំពេញទៅនឹងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ រួចហើយ។ តែដោយសារតែការបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងដល់វិធាន ៨៧(៤) មេធាវីការពារក្តីសូមដាក់សំណើនេះដើម្បីជាជំនួយដល់អង្គជំនុំជម្រះតាមរយៈការផ្តល់ព័ត៌មានបន្ថែម។

៣. ដោយសារតែជាបញ្ហាបឋមបន្ថែមទៀតនោះ មេធាវីការពារក្តីរក្សាជំហរជាបន្តបន្ទាប់របស់ខ្លួនថា នៅក្រោមច្បាប់ជាធរមាន គឺមិនមាន "តម្រូវការអំពីការជូនដំណឹងជាមុន" នោះទេ នៅក្នុងការទទួលយកឯកសារជាភស្តុតាងនៅចំពោះមុខ អវតក[2]។ តែផ្ទុយទៅវិញ បញ្ជីឯកសារបឋម និងឯកសារភស្តុតាងផ្សេងទៀត ដែលស្នើសុំដោយមេធាវីការពារក្តីនឹងត្រូវទទួលយកបាននៅពេលណាក៏បាន រហូតដល់ចប់សវនាការសំណុំរឿង ០០២/០២។ មេធាវីការពារក្តីយោងទៅលើអំណះអំណាងរបស់ខ្លួនកាលពីលើកមុន ដែលពាក់ព័ន្ធទៅនឹងបញ្ហានេះ ដែល*ក្នុងចំណោមនោះ* រួមមាននៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០១[3] ("បណ្តឹងសាទុក្ខ") និងបញ្ជីឯកសារបឋមរបស់ខ្លួនសម្រាប់សំណុំរឿង ០០២/០២[4]។ មេធាវីការពារក្តីសូមយោងជាពិសេសទៅដល់អំណះអំណាងជាក់លាក់នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនពាក់ព័ន្ធនិងការជូនដំណឹងជាមុនអំពីឯកសារដែលនឹងត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសួរដេញដោលសាក្សី និងបញ្ជាក់ថា អំណះអំណាងទាំងអស់នេះសមហេតុផលសម្រាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលជាបុគ្គលមិនគ្រាត់តែត្រូវបានអនុញ្ញាតិឲ្យជួបមេធាវីរបស់ខ្លួននៅមុនពេល

---

[2] សូមមើល ដូចជា ឯកសារ E131/1/13 "បញ្ជីឯកសារ ដែលត្រូវស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងសម្រាប់សវនាការវគ្គដំបូង" ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៥។

[3] F16 "បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤, កថាខណ្ឌ ៨៨ ដល់ ១០៤។

[4] E307/5 "បញ្ជីឯកសារសម្រាប់សំណុំរឿង ០០២/០២" ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ២ ដល់ ៤។

និងក្នុងអំឡុងពេលសវនាការប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងមិនត្រូវបានតម្រូវឲ្យធ្វើសម្បថថែមទៀតផង។

**ខ. ឯកសារដែលត្រូវបានស្នើសុំឲ្យទទួលយក**

៤. មេធាវីការពារក្តីស្នើសុំដាក់ឯកសារទាំងប្រាំនេះទាក់ទងនឹងការពិពណ៌នារបស់លោកស្រី អ៊ុំ សុផានី។ ការពិពណ៌នាអំពីភាពពាក់ព័ន្ធរបស់ឯការទាំងនេះមាននៅខាងក្រោម។ បើទោះជាជំហររបស់ខ្លួនដូចមាននៅក្នុងកថាខណ្ឌទី២ ក៏មេធាវីការពារក្តីរួមបញ្ចូលផងដែរនូវអំណះអំណាងទៅលើវិធាន ៨៧ (៤)។

៥. មេធាវីការពារក្តីស្នើសុំឲ្យទទួលយកឯកសារទាំងប្រាំដូចខាងក្រោមនេះ ("ឯកសារទាំងប្រាំ") ទាក់ទងនឹងសក្ខីកម្មរបស់លោកស្រី អ៊ុំ សុផានី៖

**(ក)** **ឯកសារទី១៖ ក្រោមដំណក់ទឹកភ្លៀង:**[5] នៅឆ្នាំ ២០១១ រោងពុម្ពបឹងទន្លេសាបបានបោះពុម្ពសៀវភៅដែលនិពន្ធដោយ អ៊ុំ សុផានី មានចំណងជើងថា *ក្រោមដំណក់ទឹកភ្លៀង*។ នៅលើគម្របសៀវភៅបញ្ជាក់ថា សៀវភៅនេះជា "រឿងពិត" ដែលនៅផ្នែកអារម្ភកថា លោកស្រី អ៊ុំ សុផានី បញ្ជាក់ថា សៀវភៅ "ប្រាប់ពីរឿងជីវិតរបស់ខ្ញុំ"។ នៅក្នុងសៀវភៅនោះលោកស្រី អ៊ុំ សុផានី បានរៀបរាប់ក្នុងចំណោមរឿងរ៉ាវផ្សេងទៀត អំពីការរៀបការដោយបង្ខំនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ជាមួយបុរសម្នាក់ឈ្មោះ ពិចិត្រ ដែលមានអាយុប្អូនគាត់ប្រាំឆ្នាំ ហើយជាបុរសដែលគាត់មិនដែលស្គាល់ពីមុនមក។

**(ខ)** **ឯកសារទី២៖ សេចក្តីប្រកាសព័ត៌មានរបស់សមាគមន៍ជនរងគ្រោះរបបខ្មែរក្រហមក្នុងប្រទេសកម្ពុជា:**[6] នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ នៅមុនពេលការចាប់ផ្តើមសវនាការក្នុងសំណុំរឿង ០០២/០១ សមាគមន៍ជនរងគ្រោះរបបខ្មែរក្រហមក្នុងប្រទេសកម្ពុជា("AKRVC") បានចេញសេចក្តីប្រកាសព័ត៌មានថា លោកស្រី អ៊ុំ សុផានី ត្រូវបានបង្ខំឲ្យរៀបការនៅថ្ងៃទី

---

[5] ឯកសារនេះអាចរកបាននៅឃ្លាំងផ្ទុកឯកសាររួម ដែលមាន ERNs 01058323-01058332។

[6] ឯកសារនេះអាចរកបាននៅឃ្លាំងផ្ទុកឯកសាររួម ដែលមាន ERNs 01058310-01058316។

១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ជាមួយបុរសម្នាក់ឈ្មោះ "ពិចិត្រ ដែលមានអាយុប្អូនគាត់ប្រាំឆ្នាំ"។ នៅក្នុងសេចក្តីប្រកាសព័ត៌មាននោះក៏មានការដកស្រង់ការត្អូញរបស់លោកស្រីថា "ខ្ញុំមានកំហឹងខ្លាំងណាស់ ហើយបានសម្រេចចិត្តថាខ្ញុំប្រហែលជាស្លាប់ប្រសើរជាង ព្រោះលើសពីប្តីម្នាក់ត្រូវបានបង្ខំមកលើខ្ញុំ"។

(គ) **ឯកសារ៣៖ អត្ថបទវិទ្យុជាតិ:**[7] នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ គេហទំព័រមួយឈ្មោះ "វិទ្យុជាតិ" បានផ្សាយអត្ថបទមួយនៅក្នុងអ៊ិនទ័ណែតអំពីលោកស្រី សុផានី ដែលដកស្រង់ដោយផ្ទាល់នូវការពិពណ៌នាអំពីអ្នកស្រី សុផានី ដោយសេចក្តីប្រកាសព័ត៌មានរបស់ AKRVC ។

(ឃ) **ឯកសារ៤៖** ***អត្ថបទកាសែតភ្នំពេញប៉ុស្តិ៍:***[8] នៅថ្ងៃទី១០-១៦ ខែ ឧសភា ការបោះពុម្ពផ្សាយ ៧ថ្ងៃប្រចាំសប្តាហ៍របស់កាសែតភ្នំពេញប៉ុស្តិ៍ បានផ្សាយអត្ថបទមួយ "អ្នកនិងខ្ញុំក្នុងសម័យប៉ុល ពត: ខ្ញុំមិនចង់សរសេរឲ្យបានលំអិតជាសាធារណៈអំពីការសម្ភាសន៍របស់លោកស្រី សុផានី និងកូនប្រុសរបស់គាត់ជាមួយអ្នកសារព័ត៌មាន Rosa Ellen។ នៅក្នុងបទសម្ភាសន៍នោះអ្នកស្រី សុផានី ត្រូវបានដកស្រង់សំដី ដោយបានពិពណ៌នាក្នុងចំណោមបញ្ហាដ៏ទៃទៀតអំពីអាពាហ៍ពិពាហ៍របស់គាត់ថាជា "ផ្នែកនៃ"ការប្តេជ្ញាចិត្ត" [...] រៀបការនៅចំពោះមុខអង្គការ"។ នៅក្នុងការដាក់ចំណងជើងនៃការសម្ភាសន៍នេះ អ្នកសារព័ត៌មានកត់សម្គាល់ថា អ្នកស្រី សុផានី "ឆ្លងកាត់អាពាហ៍ពិពាហ៍ដោយបង្ខំ"។

(ង) **ឯកសារ៥៖ ការត្រួតពិនិត្យសៀវភៅ** ***ក្រោមដំណក់ទឹកភ្លៀង:*** ***(under the Drops of Falling Rain)***[9] ផ្សាយនៅក្នុងអ៊ីនទ័ណែតគេហទំព័រមានឈ្មោះ *the Modern Novel* នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១៤ ផ្សាយវិវេចនានៃសៀវភៅរបស់លោកស្រី សុផានី មានចំណងជើងថា *ក្រោមដំណក់*

---

[7] ឯកសារនេះអាចរកបាននៅ ERN 01058317-01058319 ។

[8] ឯកសារនេះអាចរកបាននៅ ERN 0105820។

[9] ឯកសារនេះអាចរកបាននៅ ERN 01058321-01058322។

*ទឹកភ្លៀង*។ អ្នកពិនិត្យអនាមិកលំអិតពីទស្សនរបស់គាត់ថា សៀវភៅរបស់ សុផានី "គឺជាស្វ័យជីវិប្រវត្តិតាមការសន្មត" និងពិព័ណ៌នារបៀបដែលគាត់ ត្រូវបានបង្ខំរៀបការជាមួយបុរសម្នាក់ឈ្មោះ ពិចិត្រ ដែលមានអាយុតិចជាង គាត់៥ឆ្នាំ។

## គ. ភាពពាក់ព័ន្ធ និង ភាពអាចទទួលយកបាននៃឯកសារ

៦. ឯកសារទាំងប្រាំនេះហាក់ដូចជាភស្តុតាងបឋមដើម្បីបង្ហាញថា លោកស្រី សុផានី បានចេញ ដោយខ្លួនឯង ឬយ៉ាងហោចណាស់បានយល់ព្រមលើសេចក្ដីការថ្លែងជាសាធារណៈដើម្បី ចង្អុលបង្ហាញថា គាត់ត្រូវបានបង្ខំឲ្យរៀបការជាមួយកម្មាភិបាលខ្មែរក្រហមម្នាក់។ ផ្នែកនានា នៃឯកសារទាំងនេះផ្ទុយគ្នាទាំងស្រុងទៅនឹងសក្ខីកម្មរបស់លោកស្រី សុផានី នៅក្នុងកំណត់ ប្រចាំថ្ងៃនាយុគសម័យខ្មែរក្រហមរបស់គាត់ ដែលត្រូវបានដាក់បញ្ចូលជាភស្តុតាងទៅក្នុង សំណុំរឿង ហើយដែលមេធាវីរបស់គាត់លើកយកមកយោងនៅក្នុងការដាក់សំណួរដ៏វែង ចំពោះលោកស្រី សុផានី។ អាស្រ័យហេតុនេះឯកសារទាំងប្រាំពាក់ព័ន្ធយ៉ាងខ្លាំងដោយសារវា ប៉ះពាល់ដោយផ្ទាល់ទៅលើភាពអាចជឿទុកចិត្តបានជាទូទៅនៃសក្ខីកម្មរបស់ សុផានី ហើយ ដូច្នេះវាអាចជួយដល់ការបង្កើតការពិត។

៧. នៅក្នុងករណីឯកសារអាចរកបាននៅមុនការចាប់ផ្ដើមការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង បានទទួលយកជាភស្តុតាង "នៅពេលដែលផលប្រយោជន៍ខាងយុត្តិធម៌តម្រូវ ជាពិសេសនៅ ក្នុងករណីដែលជាភស្តុតាងដោះបន្ទុក និងតម្រូវឲ្យវាយតម្លៃដើម្បីបញ្ចៀសនូវភាពអយុត្តិ ធម៌"[10] ឬនៅក្នុងករណីដែលមាន "ទំនាក់ទំនងជិតស្និទ្ធជាមួយសម្ភារៈដែលមាននៅចំពោះមុខ អង្គជំនុំជម្រះ និង...ផលប្រយោជន៍ខាងយុត្តិធម៌តម្រូវឲ្យវាយតម្លៃប្រភពជាមួយគ្នា"[11]។

---

[10] E307/1 កថាខណ្ឌ៣។ សូមមើលផងដែរឯកសារ E190 "សេចក្ដីសម្រេចទាក់ទងនឹងឯកសារថ្មី និងបញ្ហា ពាក់ព័ន្ធផ្សេងៗទៀត" ចុះថ្ងៃទី៣០ ខែមេសាឆ្នាំ២០១២ នៅកថាខណ្ឌ៣៦។

[11] E289/2 "សេចក្ដីសម្រេចលើសំណើតាមវិធាន៨៧(៤)របស់មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី សុំដាក់នៅចំពោះមុខអង្គ ជំនុំជម្រះសាលាដំបូងនូវភស្តុតាងថ្មី (E289) និងចម្លើយតបរបស់ ខៀវ សំផន (E289/1) ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ នៅកថាខណ្ឌ៣។

៨. ឯកសារទាំងប្រាំនេះ ត្រូវបានបង្កើតនៅមុន "ការចាប់ផ្ដើមការជំនុំជម្រះ"។ ក្រុមមេធាវីការពារបានទទួលឯកសារទី២, ៤ និងទី៥ នៅចុងខែ វិច្ឆិកា នៅក្នុងការរៀបចំសម្រាប់សក្ខីកម្មលោកស្រី សុផានី ដែលគ្រោងធ្វើនៅពេលនោះ។ ក្រុមមេធាវីការពារកាលពីលើកមុនបានស្រាវជ្រាវរកឯកសារទី១ ហើយបានស្នើមេធាវីលោកស្រី សុផានី ឲ្យផ្ដល់សំណៅនៅមុនការស្ដាប់សក្ខីកម្មរបស់គាត់ តែសំណើនេះត្រូវបានបដិសេធ។ ក្រុមមេធាវីការពារក្ដីទទួលបានពីសាធារណជននូវសំណៅរបស់សៀវភៅនៅក្រោយការស្ដាប់សក្ខីកម្មលើកដំបូងរបស់លោកស្រី សុផានី នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ ក្រុមមេធាវីការពារក្ដីទើបតែទទួលបានឯកសារទី២ បន្ទាប់ពីការស្រាវជ្រាវបន្ថែមទាក់ទងនឹងអ្នកស្រី សុផានី នៅក្រោយការស្ដាប់សក្ខីកម្មគាត់នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ ប៉ុន្ដែបើទោះបីឯកសារទើបតែអាចរកបាននៅមុនការចាប់ផ្ដើមជំនុំជម្រះក្នុងករណី០០២/០២ ក៏ក្រុមមេធាវីការពារស្នើសុំដាក់ចូលក្នុងសំណុំរឿងនៅពេលនេះដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ដោយសារតែឯកសារទាំងនេះ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងលោកស្រី សុផានី។ អាស្រ័យដូច្នេះ សម្រាប់ករណីនេះ "ផលប្រយោជន៍យុត្តិធម៌ តម្រូវប្រភពដើមនៃឯកសារត្រូវបានវាយតម្លៃជាមួយគ្នា"។

## III. ដំណោះស្រាយ

៩. អាស្រ័យដូចបានបញ្ជាក់ក្នុងមូលហេតុខាងលើ ក្រុមមេធាវីការពារស្នើអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារចំនួនប្រាំដាក់ក្នុងសំណុំរឿង។

**សហមេធាវីការពារក្ដីលោក នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE